ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំអង្គការសហប្រជាជាតិ អង្គការពាណិជ្ជកម្មពិភពលោក
និងអង្គការអន្តរជាតិនានា នៅហ្សឺណែវ ប្រទេសស្វីស

# សេចក្តីជូនដំណឹង

ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា និងស្ថានបេសកកម្មអចិន្ត្រៃយ៍ ប្រចាំទីក្រុងហ្សឺណែវ ប្រទេសស្វីស មានទុក្ខក្រៀមក្រំបំផុត សូមជំរាបជូនបងប្អូនជនរួមជាតិកម្ពុជាទាំងអស់ នៅប្រទេសស្វីសមេត្តាជ្រាបថា:

**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់** បំផុតព្រះអង្គបានយាងចូលទីវង្គត់ នៅថ្ងៃទី ១៥ រោជ ខែភទ្របទ ឆ្នាំរោង ចត្វាស័ក ព.ស. ២៥៥៦ ត្រូវនឹងថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០១:២០ នាទី រំលងអធ្រាត (ម៉ោងនៅរាជធានីភ្នំពេញ) ក្នុងជន្មាយុ ៩០ ព្រះវស្សា ដោយព្រះជរាពាធ ។

ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា និងស្ថានបេសកកម្មអចិន្ត្រៃយ៍ ប្រចាំទីក្រុងហ្សឺណែវ ប្រទេសស្វីស នឹងរៀបចំពីការចុះហត្ថលេខាសៀវភៅកាន់ទុក្ខ ចាប់ពីថ្ងៃទី ១៧ ដល់ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ១០:០០ ដល់ ១២:០០ និងពីម៉ោង ១៥:០០ ដល់ ១៧:០០ នៅស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា នៅទីក្រុងហ្សឺណែវ (អាស័យដ្ឋាន : 3, Chemin Taverney, 1218 Grand-Saconnex, Geneva ) និងនៅស្ថានអគ្គកុងស៊ុលកិត្តិយសកម្ពុជា ប្រចាំទីក្រុងហ្សូរិក ។

សេចក្តីបានជំរាបជូនខាងលើនេះ សូមបងប្អូនជនរួមជាតិទាំងអស់ មេត្តាជ្រាបជាពត៌មាន ។

ហ្សឺណែវ ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១២

អាស័យដ្ឋាន : 3 Chemin Taverney, Case postale 213, 1218 Grand-Saconnex, Genève, Suisse
ទូរស័ព្ទ: (41 22) 788 77 73 ; ទូរសារ: (41 22) 788 77 74 ; E-mail : camemb.gva@mfa.gov.kh
Website: http://cambodiaembassy.ch